# ព្រឹទ្ធសភា

## SENATE MAGAZINE

ទស្សនាវដ្ដីប្រចាំខែមិថុនា




លេខ ២៦០ ឆ្នាំទី២២

ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២២

Issue 260 Volume 22

Before Christ 2566 Common Era 2022

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ



- សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ អគាររដ្ឋបាលវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ ........ ១
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកអគ្គរដ្ឋទូតអ៊ីស្លាមប៉ាគីស្ថាន ........ ៤
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋវ៉ាន់ដា ........ ៧
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបអគ្គលេខាធិការ នៃសម្ព័ន្ធពិភពឥស្លាម ........ ៩
- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភាអញ្ជើញបញ្ចុះបឋមសិលាសាងសង់ព្រះវិហារនៅវត្តលុម្ពិនី ហៅវត្តអូរសោម នៅខេត្តពោធិ៍សាត់ ........ ១២
- ថ្នាក់ដឹកនាំព្រឹទ្ធសភាសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ........ ១៤

## សកម្មភាពគណៈកម្មការ



- ព្រឹទ្ធសភាទទួលជំនួយសម្ភារវេជ្ជសាស្ត្រពីអង្គការចែករំលែក សង្គ្រោះអាយុជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ........ ១៦
- ព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប និមន្ត និងអញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា ........ ១៨
- សាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដា ទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា ........ ១៩
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ........ ២០
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨ ........ ២១
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........ ៣០
- ការងារទទួលពាក្យបណ្តឹង ........ ៣១

## សកម្មភាពអគ្គលេខាធិការដ្ឋាន



- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងកំណត់ទិសដៅការងារខែមិថុនា ឆ្នាំ២០២២ ........ ៣២
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ........ ៣៤

**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម អ៊ុំ សារិទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម លីម ប៊ុនហុក
ឯកឧត្តម កែវ ចាន់ណា
ឯកឧត្តម សុខ រិទ្ធី
ឯកឧត្តម ជួន ណា
ឯកឧត្តម គឹម ពិសិដ្ឋ
លោក ជួន សុខជី
លោក ទេព មករា
លោក កុក វ៉េ

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទវេតនា
កញ្ញា សុខ សុជាតា

*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២-២០២៧ នៅវិទ្យាល័យវត្តកោះ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញកាត់ខ្សែបូសម្ពោធអគាររដ្ឋបាលវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។*

**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ទូរសព្ទ៖ (855 23)211441, 211442, 211443,ទូរសារ៖ (855 23)211446**
**E-mail : oumsarith.sgsenate@gmail.com**
**Website: www.senate.gov.kh**
**www.elibrary.senate.gov.kh**
**Facebook: www.facebook.com/senateofcambodia**

# សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ អញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ អគាររដ្ឋបាលវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ




*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ អធិបតីភាពក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ*

អគាររដ្ឋបាលវិទ្យាល័យ **ជា ស៊ីម** ជ្រោយចង្វារថ្មីចំនួន ១ខ្នង កម្ពស់២ជាន់ មាន១៥បន្ទប់ស្ថិតនៅក្នុងសង្កាត់ជ្រោយ-ចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ត្រូវបានរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២២។

នាឱកាសនោះ ឯកឧត្ដម **ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ បានឡើងរាយការណ៍ជូនអង្គពិធីអំពីស្ថានភាព ទីតាំងភូមិសាស្ត្រ ការរស់នៅរបស់ប្រជាពលរដ្ឋ និងស្ថានភាពអប់រំនៅរាជធានីភ្នំពេញ។ ដោយឡែកវិទ្យាល័យ **ជា ស៊ីម** ជ្រោយចង្វារ មានទីតាំងស្ថិតនៅក្នុងភូមិ៣ ក្រុមទី១៧ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយ-ចង្វារ រាជធានីភ្នំពេញ បានបង្កើតនៅឆ្នាំ១៩៨៤-១៩៨៥ មានឈ្មោះថា អនុវិទ្យាល័យជ្រោយចង្វារ។



*ឯកឧត្ដម ឃួង ស្រេង ឡើងរាយការណ៍*

មានប្រសាសន៍ក្នុងឱកាសដ៏ថ្លៃថ្លានោះ សម្ដេចវិបុល-សេនាភក្ដី **សាយ ឈុំ** បានសម្ដែងនូវការអបអរសាទរចំពោះសមិទ្ធផលថ្មីដ៏មានសារប្រយោជន៍ និងសូមកោតសរសើរចំពោះទឹកចិត្តសប្បុរសជននានា រួមទាំងការយក-ចិត្តទុកដាក់របស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានជួយជ្រោម-ជ្រែងដល់ការកសាងអគាររដ្ឋបាលថ្មីនេះរហូតចប់រួចរាល់ជាស្ថាពរ។

សម្ដេចប្រធានព្រឹទ្ធសភាបានរំលឹកថា កាលដើមឡើយសាលារៀនមួយនេះ ត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងដោយពួកប៉ុល ពត អត់សាសនា អត់ការអប់រំ ប៉ុន្តែយើងបានកសាងឡើងវិញនៅឆ្នាំ១៩៨៤ និងដាក់ឈ្មោះថា អនុ-វិទ្យាល័យជ្រោយចង្វារ។ នៅពេលនោះ យើងខិតខំរហូតកសាងបានអគារសិក្សាធ្វើអំពីថ្មបន្ថែមជាច្រើនខ្នង និងមានសម្ភារៈសិក្សាគ្រប់គ្រាន់ ដែលផ្ដល់លទ្ធភាពឱ្យសិស្សអាចរៀនសូត្រស្រូបយកចំណេះដឹងបាន និងបានប្ដូរឈ្មោះមកជាវិទ្យាល័យ **ជា ស៊ីម** ជ្រោយចង្វារវិញ ដើម្បីឧទ្ទិសដល់គុណបំណាច់ដ៏ថ្លៃថ្លារបស់សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា ដែលបានណែនាំឱ្យធ្វើយ៉ាងណារៀបចំតំបន់នេះកុំឱ្យមានទឹកជន់លិច បង្កការលំបាកដល់សិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ការអប់រំបណ្ដុះ-បណ្ដាលធនធានមនុស្ស គឺជាកិច្ចការដ៏សំខាន់ និងចាំបាច់សម្រាប់រួមចំណែកដល់ការកសាងសង្គមអារ្យធម៌មួយប្រកបដោយសុខដុមរមនា សុភមង្គល មានសណ្ដាប់ធ្នាប់



ទិដ្ឋភាពអ្នកចូលរួមក្នុងពិធីសម្ពោធអគាររដ្ឋបាលថ្មី

និងការរីកចម្រើនជាលំដាប់។ បន្ទាប់ពីស្ថានភាពកូវីដ-១៩ បានធូរស្រាល ក្មួយៗ ក៏បានមករៀននៅសាលារៀនវិញជាធម្មតា ក្រោយពីខកខានមិនបានរៀនដូចធម្មតាអស់រយៈពេលជាង២ឆ្នាំមកនេះ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ចូលក្នុងសហគមន៍របស់យើង។ ប៉ុន្តែទោះបីជាមិនអាចមករៀនផ្ទាល់នៅសាលាក៏ពិតមែន ក៏រាជរដ្ឋាភិបាលនៅតែយកចិត្តទុកដាក់ និងប្រើគ្រប់វិធីសាស្រ្ត ដើម្បីឱ្យក្មួយៗអាចសិក្សាតាមកម្មវិធីអនឡាញ តាមកម្មវិធីទូរទស្សន៍ វិទ្យុ និងតាមកម្មវិធីក្នុងទូរស័ព្ទជាដើម។ ការខិតខំទាំងអស់នេះ គឺដើម្បីធានាថា សិស្សានុសិស្សនៅតែអាចទទួលបានការបណ្តុះបណ្តាលស្របតាមកម្មវិធី និងរៀនសម្របខ្លួនរបៀប “ការរស់នៅតាមគន្លងប្រក្រតីថ្មី”។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានចាក់វ៉ាក់សាំងជូនប្រជាជនទាំងមូល ចាប់ពីកុមារអាយុ៣ឆ្នាំឡើងទៅដោយឥតគិតថ្លៃ ទាំងការចាក់វ៉ាក់សាំងដូសដំបូង ដូសជំរុញទី១ ទី២ ទី៣ ទី៤ ទី៥ ឬដូសទី៦ក៏ដោយ។

សម្តេចប្រធានព្រឹទ្ធសភាបានសង្កត់ធ្ងន់ថា រាជរដ្ឋាភិបាលបច្ចុប្បន្នបានផ្តោតសំខាន់លើការអភិវឌ្ឍធនធានមនុស្ស ទឹក ផ្លូវ ភ្លើងវិញម្តង។ ការប្រែប្រួលចក្ខុវិស័យ គឺសុទ្ធតែត្រូវបានគិតគូរយ៉ាងហ្មត់ចត់ និងត្រឹមត្រូវពីប្រមុខរាជរដ្ឋាភិបាល ដើម្បីប្រទេសកម្ពុជាបន្តទទួលបានការរីកចម្រើនជាលំដាប់តាមលំអានរបស់ពិភពលោក និងដើម្បីប្រជាពលរដ្ឋបន្តរស់នៅដោយសុខសន្តិភាព មានជីវភាពប្រសើរឡើង ទោះបីជាពេលខ្លះ យើងទាំងអស់គ្នាត្រូវប្រឈមនឹងការលំបាកដែលមិនធ្លាប់ជួបពីមុន ដូចជាការរាតត្បាតនៃជំងឺកូវីដ-១៩ និងដោយវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនក្តី អ្វីដែលរាជរដ្ឋាភិបាលធានាបានជូនប្រជាពលរដ្ឋគ្រប់ៗរូប គឺសុខសន្តិភាព ដែលយើងគ្រប់គ្នារកបានមកដោយលំបាក។ យើងមិនត្រូវបំភ្លេចចំណុចនេះឡើយ និងត្រូវរំលឹកបង្រៀនដល់ក្មេងៗជំនាន់ក្រោយពីគុណតម្លៃនៃសន្តិភាព ដោយបង្ហាញឱ្យពួកគេឃើញ និងយល់ថា “បើគ្មានសន្តិភាព គឺគ្មានអ្វីៗទាំងអស់”។ ហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ និងសមិទ្ធផលជាច្រើនរាប់មិនអស់ត្រូវបានកសាង និងអភិវឌ្ឍនៅទូទាំងប្រទេស មិនអាចកើតឡើងដោយឯកឯងបានទេ ប្រសិនបើគ្មាន “សន្តិភាព”។

សម្តេចប្រធានព្រឹទ្ធសភាបានមានប្រសាសន៍ថា ប្រទេសកម្ពុជាបាននឹងកំពុងតែឈរស្មើមុខ ស្មើមាត់ នឹងប្រទេសដទៃទាំងអស់នៅលើពិភពលោក។ ក្នុងឆ្នាំ២០២១ កន្លងមកនេះ កម្ពុជាបានទទួលធ្វើជាប្រធានដឹកនាំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ តាមប្រព័ន្ធវីដេអូ ដែលមានការចូលរួមពីថ្នាក់ដឹកនាំមកពីបណ្តាប្រទេសនៅអឺរ៉ុប និងអាស៊ីជាង៥៨ប្រទេស។ ក្នុងខែឧសភាថ្មីៗកន្លងមកនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន-អាមេរិក ក្នុងនាមជាសហប្រធានដឹកនាំអង្គប្រជុំជាមួយ ឯកឧត្តម **ចូ បៃដិន** ប្រធានាធិបតីសហរដ្ឋអាមេរិក ដែលនេះគឺជាមោទកភាពដ៏ធំបំផុតរបស់ប្រទេសជាតិយើង។ ការធ្វើជាម្ចាស់ផ្ទះ និងដឹកនាំកិច្ចប្រជុំកំពូលកម្រិតតំបន់ និងពិភពលោកនេះ បានសបញ្ជាក់ឱ្យឃើញថា ក្រោមចក្ខុវិស័យដ៏វែងឆ្ងាយ និងភាពប៉ិនប្រសព្វផ្នែកនយោបាយការទូតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ពិតជាបានធ្វើឱ្យពិភពលោក ស្ញប់ស្ញែងកោតសរសើរ និងបានប្រគល់ពានរង្វាន់សន្តិភាព ស៊ុនហាក់ (SUNHAK) របស់អង្គការ

សម្ព័ន្ធសន្តិភាពសកល នៃសាធារណរដ្ឋកូរ៉េខាងត្បូង ជូនសម្ដេចនាយករដ្ឋមន្ត្រី ថែមទៀតផង។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ចាប់តាំងពីប្រទេសកម្ពុជាទទួលយករបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្សមក កម្ពុជាបានរៀបចំការបោះឆ្នោតទាំងថ្នាក់ជាតិ និងទាំងថ្នាក់ក្រោមជាតិ ស្របតាមការកំណត់របស់រដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមានជាទៀងទាត់។ ថ្មីៗកន្លងមកនេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សានៅទូទាំងប្រទេស ហើយយើងសង្ឃឹមថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ នាឆ្នាំ២០២៣នឹងប្រព្រឹត្តទៅដោយរលូន។ សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់បន្ថែមថា ជានិច្ចកាល រាជរដ្ឋាភិបាលតែងតែផ្ដល់អាទិភាពទី១ លើការអភិវឌ្ឍធនធានមនុស្ស ដើម្បីលើកស្ទួយ និងអភិវឌ្ឍវិស័យអប់រំកម្ពុជា ពោលគឺបន្តធានានូវសេវាអប់រំ ដែលមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំ នឹងបន្តដោះស្រាយរាល់ការខ្វះខាតក្នុងវិស័យអប់រំនេះទៅតាមកំណើននៃសិស្សានុសិស្ស មិនថាតែនៅទីក្រុង ឬតាមទីជនបទឡើយ។ អាស្រ័យហេតុនេះ សូមអាជ្ញាធរគ្រប់លំដាប់ថ្នាក់ បន្តផ្សារភ្ជាប់ឱ្យកាន់តែជិតស្និទ្ធជាមួយនឹងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ជាពិសេសចៅសង្កាត់ និងថ្នាក់ដឹកនាំសង្កាត់ ត្រូវបន្តកាយវិការយ៉ាងសកម្មក្នុងការបម្រើប្រជាជនបែបនេះ និងធ្វើឱ្យកាន់តែច្រើនឡើងថែមទៀត។

សម្ដេចប្រធានព្រឹទ្ធសភាបានអំពាវនាវដល់គ្រប់សាលារៀនទាំងអស់ សូមយកចិត្តទុកដាក់ខ្ពស់ចំពោះកម្មវិធីសិក្សាដែលអាចជួយឱ្យសិស្សានុសិស្សទទួលបាននូវគុណវុឌ្ឍិមួយចំនួនដូចជា៖ (១)អាចយល់ដឹងអំពីអ្វីដែលខុស និងអ្វីដែលត្រូវ (២)មានគំនិតច្នៃប្រឌិត (៣)ចេះគោរព និងចេះប្រើពាក្យសម្ដី និងអាកប្បកិរិយាគួរសមចំពោះមនុស្សគ្រប់រូប (៤)ចេះគោរពស្រឡាញ់ខ្លួនឯង គ្រួសារ និងអ្នកដទៃ និង(៥)ចូលចិត្តសកម្មភាពដែលនាំមកនូវសុខភាពល្អ និងការរីកចម្រើនទាំងផ្នែករាងកាយ និងបញ្ញា។ ជាមួយគ្នានោះ សម្ដេចក៏បានអំពាវនាវដល់អ្នកគ្រូ លោកគ្រូ និងអាណាព្យាបាលគ្រប់រូប ត្រូវចូលរួមអប់រំកូន ឱ្យគាត់ចាកឆ្ងាយពីការប្រើប្រាស់បណ្ដាញសង្គមដែលសម្បូរទៅដោយការអូសទាញបែបអបាយមុខ ព័ត៌មានហិង្សា ព័ត៌មានក្លែងក្លាយ ដែលនាំឱ្យយុវវ័យញៀនងប់ងល់នឹងទូរស័ព្ទ រហូតដល់គ្មានការផ្ដោតអារម្មណ៍រៀន ជាពិសេសអាចឈានទៅដល់ការប្រព្រឹត្តអំពើអបាយមុខនានា ដែលបំផ្លាញខ្លួនឯងផង គ្រួសារផង និងសង្គមជាតិផង។

សូមជម្រាបថា អគាររដ្ឋបាលថ្មី១ខ្នង កម្ពស់២ជាន់ មាន ១៥បន្ទប់ ស្ថិតក្នុងបរិវេណវិទ្យាល័យ **ខា ស៊ីម** ជ្រោយចង្វារមានបណ្ដោយប្រវែង៤៩ម៉ែត្រ និងទទឹង៩,៧ម៉ែត្រ ធ្វើអំពីឥដ្ឋប្រក់ក្បឿង ចាប់ផ្ដើមសាងសង់នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០ បានបញ្ចប់ការសាងសង់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ដែលបានចំណាយថវិកាអស់ចំនួន២៥ម៉ឺនដុល្លារអាមេរិក ដែលជាអំណោយរបស់លោកឧកញ៉ា **លៀង ផន** និងលោកជំទាវ **ឈឹម ណារី**។

(អត្ថបទ៖ ធុន គីមជី រូបភាព៖ វង់ សុជាតិ)





*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ថតរូបអនុស្សាវរីយ៍*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកអគ្គរដ្ឋទូតអ៊ីស្លាមប៉ាគីស្ថាន



*ឯកឧត្តម ហ្សាហៀរុឌីន បាបា ថាហ៊ីម និងសម្តេច សាយ ឈុំ*

នាព្រឹកថ្ងៃសុក្រ ទី២៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៩:០០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម **ហ្សាហៀរុឌីន បាបា ថាហ៊ីម** (Zaheeruddin Babar Thaheem) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងអំណរសាទរស្វាគមន៍ចំពោះឯកឧត្តម **ហ្សាហៀរុឌីន បាបា ថាហ៊ីម** ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ប្រចាំព្រះរាជាណាចក្រកម្ពុជា។ សម្តេចប្រធានព្រឹទ្ធសភាមានជំនឿជឿជាក់ថា តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តម ឯកឧត្តមនឹងខិតខំបន្តលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដែលមានស្រាប់រវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់ប្រជាជន និងប្រទេសទាំងពីរទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងឱកាសនោះ ឯកឧត្តម **ហ្សាហៀរុឌីន បាបា ថាហ៊ីម** បានសម្តែងនូវសេចក្តីរីករាយដែលទទួលបាននូវការគាំទ្រពីរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។ ឯកឧត្តមបានកត់សម្គាល់ថា ក្នុងរយៈពេលជាងពីរឆ្នាំកន្លងទៅនេះ គឺជាពេលវេលាដ៏លំបាកសម្រាប់ទំនាក់ទំនងរវាងប្រទេសទាំងពីរ អាស្រ័យដោយពិភពលោកបានជួបប្រទះនូវការរីករាលដាលនៃជំងឺកូវីដ-១៩។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្តក្នុងការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ នៃប្រទេសទាំងពីរបន្ថែមទៀត។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានសម្តែងនូវការអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះប្រទេសកម្ពុជាក្នុងការគ្រប់គ្រងជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កម្ពុជា





*ទិដ្ឋភាពចូលជួបសម្តែងការគួរសម*



*ទិដ្ឋភាពជំនួបសម្ដែងការគួរសម*

បានទទួលនូវសមិទ្ធផលដ៏អស្ចារ្យក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងការគ្រប់គ្រងជំងឺកូវីដ-១៩ ហើយប្រទេសកម្ពុជាបានបើកដំណើរការពេញលេញឡើងវិញ។ ជាពិសេសក្នុងរយៈពេលថ្មីៗនេះ មិនមានការឆ្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ឡើយ។

ក្នុងឱកាសនោះ សម្ដេចប្រធានព្រឹទ្ធសភាបានរំលឹកអំពីការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៥២។ សម្ដេចបានសម្ដែងនូវការអបអរសាទរដ៏ក្លៀវក្លាជាមួយនឹងប្រជាជន រដ្ឋាភិបាល សភានៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ក្នុងឱកាសដែលទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរឈានចូលខួបលើកទី៧០ឆ្នាំ។ សម្ដេចបានប្រសិទ្ធពរឱ្យចំណងមិត្តភាព និងសហប្រតិបត្តិការរវាងប្រទេសទាំងពីរស្ថិតស្ថេរចីរកាល។

សម្ដេចប្រធានព្រឹទ្ធសភាបានកត់សម្គាល់ដោយសេចក្ដីរីករាយចំពោះទំនាក់ទំនងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានការរីកចម្រើនជាបន្តបន្ទាប់។ ទំនាក់ទំនងល្អនេះ កើតឡើងតាមរយៈការផ្លាស់ប្ដូរទស្សនកិច្ចទៅវិញទៅមករវាងថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ នៃប្រទេសទាំងពីរ និងការគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ដើម្បីរួមចំណែកលើកកម្ពស់ទំនាក់ទំនងរវាងព្រឹទ្ធសភាទាំងពីរ ព្រឹទ្ធសភាកម្ពុជាបានបង្កើតក្រុមមិត្តភាពព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន។ ព្រឹទ្ធសភាទាំងពីរបានគាំទ្រគ្នាជាបន្តបន្ទាប់នៅក្នុងក្របខ័ណ្ឌអន្តរសភា ជាពិសេសសហភាពអន្តរសភា (IPU) និងសភាតំបន់អាស៊ី (APA)។

សម្ដេចប្រធានព្រឹទ្ធសភាបានស្នើឯកឧត្តមឯកអគ្គរដ្ឋទូតជួយសម្របសម្រួលឱ្យអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃប្រទេសទាំងពីរ បានឈានទៅដល់ការចុះហត្ថលេខាបន្តលើអនុស្សរណៈយោគយល់គ្នារយៈពេល៥ឆ្នាំបន្តទៀត ពីព្រោះអនុស្សរណៈនៃការយោគយល់គ្នា ដែលអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃប្រទេសទាំងពីរបានចុះហត្ថលេខានាពេលកន្លងទៅបានផុតសុពលភាពហើយ។

សម្ដេចប្រធានព្រឹទ្ធសភាបានជម្រាបជូនឯកឧត្តមឯកអគ្គរដ្ឋទូតជ្រាបផងដែរថា ក្នុងឆ្នាំ២០២២នេះ សភាកម្ពុជាធ្វើជាប្រធានប្ដូរវេនមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ ដែលនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកាខាងមុខនេះ។ ក្នុងនាមសភាកម្ពុជា សម្ដេចបានអញ្ជើញសភាប៉ាគីស្ថាន ដែលជាសមាជិកសង្កេតការណ៍របស់ (AIPA) ចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) នៅព្រះរាជាណាចក្រកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាបានកត់សម្គាល់ឃើញថា ទំហំនៃការផ្លាស់ប្ដូរពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍រវាងប្រទេសទាំងពីរ នៅមានកម្រិតនៅឡើយ។ សម្ដេចមានជំនឿជឿជាក់ថា បេសកកម្មការទូតរបស់ឯកឧត្តមឯកអគ្គរដ្ឋទូត ឯកឧត្តមនឹងជួយជំរុញឱ្យមានការវិនិយោគពីប៉ាគី-

ស្ថានមកកម្ពុជាឱ្យបានកាន់តែច្រើន និងជំរុញការផ្លាស់ប្តូរពាណិជ្ជកម្ម ទេសចរណ៍ រវាងប៉ាគីស្ថាន-កម្ពុជាឱ្យកាន់តែមានកំណើនកាន់តែខ្ពស់ឡើង ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនិងវិបុលភាពសម្រាប់ប្រជាជន នៃប្រទេសទាំងពីរ។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានឯកភាពចំពោះប្រសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចប្រធានព្រឹទ្ធសភា ដែលលើកឡើងអំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិកាដ៏ល្អប្រពៃរវាងប្រទេសទាំងពីរ ជាពិសេសរវាងអន្តរសភា នៃប្រទេសទាំងពីរ។ ឯកឧត្តមបានថ្លែងអំណរគុណចំពោះសម្តេចប្រធានព្រឹទ្ធសភា ដែលបានរំលឹកអំពី ការចុះអនុស្សរណៈនៃការយោគយល់គ្នាថ្មីរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប៉ាគីស្ថាន។

ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមឯកអគ្គរដ្ឋទូតបានពាំនាំនូវការអញ្ជើញរបស់ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន សូមគោរពអញ្ជើញសម្តេចប្រធានព្រឹទ្ធសភាទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប៉ាគីស្ថាន នៅពេលវេលាសមស្របណាមួយ ហើយនេះជាឱកាសក្នុងការលើកម្ពស់នូវទំនាក់ទំនង មិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងសភា នៃប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត និងជាឱកាសឱ្យអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃប្រទេសទាំងពីរ បានចុះហត្ថលេខាបន្តលើអនុស្សរណៈនៃការយោគយល់គ្នាជាថ្មី ដើម្បីជាប្រយោជន៍រវាងប្រទេសទាំងពីរ។

សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណចំពោះឯកឧត្តមប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ដែលបានអញ្ជើញសម្តេចទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន។ សម្តេចបានទទួលការអញ្ជើញនេះ ហើយសម្តេចនឹងខិតខំរកពេលវេលាសមស្របដើម្បីបំពេញទស្សនកិច្ចនៅសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន។

សម្តេចបានបញ្ជាក់ថា ដូចអ្វីដែលឯកឧត្តមឯកអគ្គរដ្ឋទូតមានប្រសាសន៍ពីខាងដើមហើយថា ប្រទេសកម្ពុជាកំពុងធ្វើយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ដែលបានចាប់ផ្តើមតាំងពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ រហូតមកដល់ថ្ងៃនេះ ពុំទាន់មានអំពើហិង្សាណាមួយកើតឡើងនោះទេ។ សម្តេចអាចវាយតម្លៃបានថា គណបក្សទាំង១៧ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត បាននឹងកំពុងធ្វើសកម្មភាពឃោសនារកសំឡេងគាំទ្រ ដោយសេរី គ្មានការរំខាន និងរឹតត្បិត ព្រមទាំងធានាបាននូវសណ្តាប់ធ្នាប់ និងសុវត្ថិភាពល្អ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាខិតខំធានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា ហើយទាំងអស់គ្នាអាចទទួលយកបាន។

តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូត សម្តេចប្រធានព្រឹទ្ធសភាបានផ្តាំផ្ញើនូវការសួរសុខទុក្ខដោយសេចក្តីគោរពរាប់អាន សេចក្តីនឹករលឹកជូនចំពោះឯកឧត្តមប្រធានព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន។ ជាមួយគ្នានោះ សម្តេចក៏បានអញ្ជើញឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន មកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ក្នុងពេលវេលាសមស្របណាមួយ។

សម្តេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនឯកឧត្តមឯកអគ្គរដ្ឋទូត មានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ និងរូបភាព៖ គង់ យ៉ារីន)



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ថតរូបអនុស្សាវរីយ៍
ជាមួយឯកអគ្គរដ្ឋទូតអ៊ីស្លាមប៉ាគីស្ថាន*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋរវ៉ាន់ដា



*លោកជំទាវ Dalila Yasmin AMRI SUED និងសម្តេច សាយ ឈុំ*

នាព្រឹកថ្ងៃពុធ ទី៨ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៩:០០នាទី សម្តេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យលោកជំទាវ Dalila Yasmin AMRI SUED ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋរវ៉ាន់ដា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានស្វាគមន៍ និងអបអរសាទរចំពោះលោកជំទាវ Dalila Yasmin AMRI SUED ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋរវ៉ាន់ដា ប្រចាំព្រះរាជាណាចក្រកម្ពុជា។

សម្តេចមានជំនឿជឿជាក់ថា ក្នុងអាណត្តិបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជាលោកជំទាវនឹងខិតខំលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់ប្រជាជន និងប្រទេសទាំងពីរ ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងឱកាសនោះ លោកជំទាវ Dalila Yasmin AMRI SUED បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចប្រធានព្រឹទ្ធសភាដែលបានចំណាយពេលវេលាដ៏មានតម្លៃទទួលជួបលោកជំទាវ។ លោកជំទាវបានរំលឹកអំពីប្រវត្តិសាស្ត្រដ៏ជូរចត់របស់ប្រទេសរវ៉ាន់ដា ដែលធ្លាប់បានឆ្លងកាត់នូវរបបប្រល័យពូជសាសន៍ដូចប្រទេសកម្ពុជាដែរ។

លោកជំទាវឯកអគ្គរដ្ឋទូតបានបញ្ជាក់ថា តាមរយៈបេសកកម្មការទូតរបស់លោកជំទាវនៅព្រះរាជាណាចក្រកម្ពុជា លោកជំទាវនឹងខិតខំប្រឹងប្រែងលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរបន្ថែមទៀត ជាពិសេសការសិក្សាឈ្វេងយល់អំពី ក្របខ័ណ្ឌសហប្រតិបត្តិការ នៃសេដ្ឋកិច្ចអាស៊ាន និងសេដ្ឋកិច្ចនៅទ្វីបអាហ្វ្រិក។

លោកជំទាវឯកអគ្គរដ្ឋទូតបានបញ្ជាក់ថា តាមរយៈបេសកកម្មការទូតនេះ គឺជាឱកាសមួយ ដើម្បីសិក្សាឈ្វេងយល់អំពីបទពិសោធន៍ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មនានារបស់អាស៊ាន ជាពិសេសក្នុងពេលដែលប្រទេសកម្ពុជាធ្វើជាប្រធានប្ដូរវេនអាស៊ាន។

លោកជំទាវឯកអគ្គរដ្ឋទូតបានសម្តែងនូវការអបអរសាទរចំពោះលទ្ធផល នៃការចាក់វ៉ាក់សាំងខ្ពស់ ប្រកបដោយសុវត្ថិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងសូមចូលរួមអបអរសាទរចំពោះអត្រាខ្ពស់ នៃការចូលរួមបោះឆ្នោតរបស់ប្រជាជនកម្ពុជាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កន្លងទៅថ្មីៗ។

សម្តេចប្រធានព្រឹទ្ធសភាបានកត់សម្គាល់ឃើញអំពីទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងវិស័យមួយចំនួនទៀតរវាងប្រទេសទាំងពីរនៅពុំទាន់បានទូលំទូលាយ។ សម្តេចសង្ឃឹមថា ក្នុងអាណត្តិបេសកកម្មការទូតរបស់លោកជំទាវឯកអគ្គរដ្ឋទូត នឹងខិតខំប្រឹងប្រែងលើកទឹកចិត្តឱ្យរដ្ឋាភិបាល នៃប្រទេសទាំងពីរ បង្កើតយន្តការពិគ្រោះយោបល់ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ និងកិច្ចសហប្រតិបត្តិការពហុភាគីឱ្យបានកាន់តែទូលំទូលាយ ដើម្បីរួមចំណែកដល់ការនាំមកនូវសន្តិភាព ស្ថិរភាព ការអភិវឌ្ឍតំបន់ និងពិភពលោក។

ដូចអ្វីដែលលោកជំទាវបានលើកឡើងអំពី ការឆ្លងកាត់របបប្រល័យពូជសាសន៍ សម្តេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាបានអនុវត្តគោលនយោបាយឈ្នះឈ្នះ ហើយទទួលបានសន្តិភាពទាំងស្រុងនៅឆ្នាំ១៩៩៨។ ចាប់ពីពេលនោះរហូតមកដល់មុនវិបត្តិកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាមានកំណើនក្នុងអត្រាប្រចាំឆ្នាំរង្វង់៧%។ ឆ្នាំ២០២០ ក្នុងបរិបទកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះមក -៣,១%។ ប្រទេសកម្ពុជាបានចាក់វ៉ាក់សាំងជូនប្រជាជនទាំងមូលចាប់ពីកុមារអាយុ៣ឆ្នាំឡើងទៅដោយឥតគិតថ្លៃ។ ដោយឃើញប្រសិទ្ធភាពនៃការចាក់វ៉ាក់សាំងនេះ ទាំងការចាក់វ៉ាក់សាំងដូស



*ទិដ្ឋភាពចូលជួបសម្ដែងការគួរសម*

ដំបូង និងដូសជំរុញ (ដូសទី១ ទី២ និងទី៣ ) មានប្រសិទ្ធភាព។ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានសម្រេចបើកដំណើរការសង្គម-សេដ្ឋកិច្ចពេញលេញតាមគន្លងប្រក្រតីភាពថ្មីនៅខែវិច្ឆិកា ឆ្នាំ២០២១។ ចាប់ពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២ កម្ពុជានឹងរៀបចំចាក់វ៉ាក់សាំងដូសជំរុញទី៥ ហើយតាមការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) សេដ្ឋកិច្ចកម្ពុជានឹងកើនឡើងវិញក្នុងអត្រា ៥,៣% ក្នុងឆ្នាំ២០២២ និង៦,៥% ក្នុងឆ្នាំ២០២៣។

ជាពិសេសកាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ កម្ពុជាបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ដែលមានគណបក្សនយោបាយចំនួន១៧ ចូលរួមប្រកួតប្រជែង។ ប្រជាជនចេញទៅបោះឆ្នោតមានចំនួន ៨០,១៩%។ ដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយតម្លាភាព គ្មានអំពើហិង្សា គ្មានការគំរាមកំហែង ដោយសន្តិភាព សេរី ត្រឹមត្រូវ យុត្តិធម៌ ហើយត្រូវបានអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិវាយតម្លៃយ៉ាងខ្ពស់ថា គឺជាការបោះឆ្នោតមួយដែលប្រកបដោយសេរី យុត្តិធម៌ និងមានស្តង់ដារអន្តរជាតិ។

សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការអបអរសាទរចំពោះសភាវ៉ាន់ដាធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតសភានិយាយភាសាបារាំងលើកទី៤៧ (APF) នៅដើមខែកក្កដា ឆ្នាំ២០២២ និងមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៥ (IPU145) នៅដើមខែតុលា ឆ្នាំ២០២២ ខាងមុខ។ សភាកម្ពុជាបានសម្រេចចាត់តាំងគណៈប្រតិភូទៅចូលរួមមហាសន្និបាតសភានិយាយភាសាបារាំង និងគ្រោងចាត់គណៈប្រតិភូទៅចូលរួមមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៥ ដ៏មានសារសំខាន់នេះផងដែរ។

តាមរយៈលោកជំទាវឯកអគ្គរដ្ឋទូត សម្ដេចប្រធានព្រឹទ្ធសភាសូមឱ្យលោកជំទាវជួយពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខប្រកបដោយក្ដីគោរព រាប់អាន សេចក្ដីស្រលាញ់អំពីព្រឹទ្ធសភា និងសម្ដេច ជូនចំពោះឯកឧត្តមប្រធានព្រឹទ្ធសភា និងថ្នាក់ដឹកនាំកំពូល នៃសាធារណរដ្ឋវ៉ាន់ដា។ ជាមួយគ្នានោះ សម្ដេចបានគោរពអញ្ជើញឯកឧត្តមប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋវ៉ាន់ដា មកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា នាពេលវេលាសមស្របណាមួយ។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាបានត្រៀមខ្លួនជានិច្ច ដើម្បីបន្តធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងលោកជំទាវឯកអគ្គរដ្ឋទូត និងស្ថានទូតវ៉ាន់ដាប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកបន្តពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការសម្រាប់ផលប្រយោជន៍ទៅវិញទៅមករបស់ប្រជាជន និងប្រទេសទាំងពីរ។

សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនលោកជំទាវឯកអគ្គរដ្ឋទូត មានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតរបស់លោកជំទាវ នៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ និងរូបភាព៖ គង់ យ៉ារីន)



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ថតរូបអនុស្សាវរីយ៍
ជាមួយឯកអគ្គរដ្ឋទូតវ៉ាន់ដា*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបអគ្គលេខាធិការ នៃសម្ព័ន្ធពិភពឥស្លាម



ឯកឧត្តម មហាំម៉ាត់ អាប់ឌុលការី អាល់អ៊ីសា និងសម្តេច សាយ ឈុំ

នារសៀលថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ១៤:៣០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យគណៈប្រតិភូសម្ព័ន្ធពិភពឥស្លាមដឹកនាំដោយឯកឧត្តម **មហាំម៉ាត់ អាប់ឌុលការី អាល់អ៊ីសា** (MOHAMMAD ABDULKARIM A ALISSA) អគ្គលេខាធិការ នៃសម្ព័ន្ធពិភពឥស្លាម និងជាប្រធានសមាគមសម្ព័ន្ធបញ្ញវន្តឥស្លាម ចូលជួបសម្តែងការគួរសម ក្នុងឱកាសដែលឯកឧត្តមដឹក-នាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រ-កម្ពុជា។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅ និងមានជំនឿជឿជាក់ថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនាឱកាសនេះ ពិតជានឹងនាំមកនូវការពង្រឹង-ពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រជាជនទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីជាគុណប្រយោជន៍សម្រាប់ប្រជាជន និងប្រទេសទាំងពីរ ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងនាមគណៈប្រតិភូ ឯកឧត្តម **មហាំម៉ាត់ អាប់ឌុល-ការី អាល់អ៊ីសា** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចប្រធានព្រឹទ្ធសភា ដែលបានទទួលបដិសណ្ឋារ-កិច្ចយ៉ាងកក់ក្តៅចំពោះគណៈប្រតិភូនាពេលនេះ។ ឯកឧត្តមបានថ្លែងនូវការកោតសរសើរ និងស្ញប់ស្ញែងចំពោះប្រទេសកម្ពុជា ដែលទទួលបាននូវសុខដុមនីយកម្មជាតិសាសន៍ និងសាសនា ដែលផ្តល់ឱ្យប្រជាជនគ្រប់រូប មិនថាកាន់សាសនាណាទេទទួលបាននូវភាពសុខដុមរមនាក្នុងការរស់នៅជាមួយគ្នា និងធ្វើឱ្យប្រទេសមានសុខសន្តិភាព។ ពិភពលោកពិតជាត្រូវការសន្តិភាព។ ប្រទេសកម្ពុជា គឺជាផ្នែកមួយនៃពិភពលោក ដែលទទួលបាននូវសុខសន្តិភាពនេះ ទោះបីមានភាពចម្រុះខាងសាសនាក៏ដោយ។ ប្រទេសកម្ពុជាមានស្ថិរភាព ការគោរពសិទ្ធិសេរីភាព ការគោរពរដ្ឋ-ធម្មនុញ្ញ និងច្បាប់ជាធរមាន ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល។ ប្រទេសកម្ពុជា





គណៈប្រតិភូសម្ព័ន្ធពិភពឥស្លាម និងសមាជិកព្រឹទ្ធសភា ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



*ទិដ្ឋភាពជំនួបសម្តែងការគួរសម*

ក៏ជាទីតាំងអនុវត្តជាក់ស្តែងដែលបង្ហាញអំពីការអនុវត្តជាក់-ស្តែងអំពីការគោរពសិទ្ធិមនុស្ស និងសុខដុមនីយកម្មខាងសាសនា។

ឯកឧត្តម **មហាំម៉ាត់ អាប់ឌុលការី អាល់អ៊ីសា** បានបញ្ជាក់ថា ប្រទេសកម្ពុជាកើតចេញពីឆន្ទៈរបស់ប្រជា-ពលរដ្ឋ។ ក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាបានយកឈ្នះលើរបបប្រល័យពូជសាសន៍ប៉ុលពត ហើយប្រជាជនកម្ពុជាមានការយល់ដឹងអំពីគុណតម្លៃនានា ក្លាយជាប្រទេសគំរូនៅលើពិភពលោកក្នុងការផ្តល់នូវសុខសន្តិភាព និងផ្តល់នូវសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋរបស់ខ្លួន។ ទាំងនេះជាភាតរភាពរបស់ប្រជាជនកម្ពុជា ក្នុងការលះបង់ ដើម្បីទទួលបាននូវសុខសន្តិភាព និងស្ថិរភាព ហើយពិភពលោកទាំងមូលពិតជាត្រូវការសុខសន្តិភាព ត្រូវការសុខដុមនីយកម្ម និងពង្រីកនូវគោលការណ៍ ដើម្បីផ្តល់នូវសុខសន្តិភាពដូចអ្វីដែលកំពុងកើតមាននៅប្រទេសកម្ពុជា។

ឯកឧត្តម **មហាំម៉ាត់ អាប់ឌុលការី អាល់អ៊ីសា** បានសន្យាថា នឹងពាំនាំនូវអ្វីដែលកើតឡើងនៅប្រទេសកម្ពុជាក្នុងបរិយាកាសប្រកបទៅដោយភាតរភាព និងជាប្រទេសដែលបានប្រឆាំងដាច់ខាតជាមួយនឹងការប្រកាន់ពូជសាសន៍ និងភាពជ្រុលនិយមផ្សេងៗ ដើម្បីជូនទៅដល់ពិភពលោកទាំងមូលអាចទាញយកបាននូវបទពិសោធន៍ក៏ដូចជាមេរៀនដ៏ល្អប្រពៃពីប្រទេសកម្ពុជា។ ជាមួយគ្នានោះ ឯកឧត្តមបានសន្យានឹងបន្តផ្តល់ដល់ប្រទេសកម្ពុជានូវជំនួយមនុស្សធម៌ផ្សេងៗ មិនត្រឹមតែសម្រាប់ប្រជាជនសាសនិកឥស្លាមប៉ុណ្ណោះទេ គឺចំពោះប្រជាពលរដ្ឋគ្រប់ៗរូបដោយមិនមានការបែងចែកជាតិសាសន៍ និងសាសនាឡើយ។

សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណចំពោះប្រសាសន៍ដ៏ល្អប្រពៃរបស់ឯកឧត្តមប្រធានគណៈប្រតិភូដែលបានថ្លែងសរសើរអំពីប្រទេសកម្ពុជា។ សម្តេចបានវាយតម្លៃខ្ពស់ចំពោះតួនាទីរបស់អង្គការសម្ព័ន្ធពិភពឥស្លាមក្នុងការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើកកម្ពស់មនុស្សធម៌ក្នុងពិភពលោក ដែលបានរួមចំណែកដោះស្រាយបញ្ហារបស់បណ្តាប្រទេសមូស្លីម ទប់ស្កាត់ជម្លោះរក្សាទំនាក់ទំនងអរិយធម៌ និងពង្រីកការសន្ទនា រួមចំណែកដល់សន្តិភាពនៃបណ្តាប្រទេសកាន់សាសនាឥស្លាម និងសន្តិភាព ស្ថិរភាពជាសកល។ ជាមួយគ្នានោះ សម្តេចក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងសម្ព័ន្ធពិភពឥស្លាម ជាមួយនឹងគណៈដឹកនាំជាន់ខ្ពស់នៃសាសនា-ឥស្លាម-កម្ពុជា។ សម្តេចបានថ្លែងអំណរគុណចំពោះសម្ព័ន្ធឥស្លាម ដែលបានផ្តល់ជំនួយមនុស្សធម៌ដល់ជនរងគ្រោះដោយទឹកជំនន់ក្នុងឆ្នាំ២០២១ ចំនួនជាង១.៥០០គ្រួសារនៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ព្រមទាំងជួយ



សម្ដេចវិបុលសេនាភក្តី សាយ ឈុំ ថតរូបអនុស្សាវរីយ៍ជាមួយនឹងគណៈប្រតិភូសម្ព័ន្ធពិភពឥស្លាម

គាំទ្រដល់ពិធីបុណ្យសាសនានានារបស់សាសនាឥស្លាម។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា នៅប្រទេសកម្ពុជា សិទ្ធិ និងសេរីភាពខាងជំនឿសាសនារបស់ប្រជាពលរដ្ឋត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ក្រោមការដឹកនាំរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ព្រះរាជាណាចក្រកម្ពុជាមានសុខដុមនីយកម្មគ្រប់សាសនាទាំងអស់នៅក្នុងប្រទេស និងសុខដុមនីយកម្មជាមួយនឹងគ្រប់សាសនាផ្លូវការទាំងអស់លើពិភពលោក រួមទាំងសាសនាឥស្លាមផងដែរ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ក្នុងបរិបទរីករាលដាលជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ផ្តល់ការចាក់វ៉ាក់សាំងជូនបងប្អូនសាសនិកឥស្លាម ព្យាបាលជំងឺ និងផ្តល់ដីសម្រាប់ជាទីបញ្ចុះសពសាសនិកឥស្លាមតាមប្រពៃណីទំនៀមទម្លាប់របស់ឥស្លាមដែលបានស្លាប់ដោយសារជំងឺកូវីដ-១៩។ ចំពោះម៉ាស្ជិទ សូរ៉ាវ ទីស្នាក់ការថ្វាយបង្គំ រាជរដ្ឋាភិបាលបានបើកដំណើរការឱ្យសាសនិកឥស្លាមប្រតិបត្តិសាសនារបស់ខ្លួនឡើងវិញ ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០២១។ ប្រទេសកម្ពុជាបានបើកប្រទេសឡើងវិញលើគ្រប់វិស័យ រួមទាំងវិស័យទេសចរណ៍ផងដែរ ចាប់តាំងពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។ ដោយសារយុទ្ធសាស្ត្រការចាក់វ៉ាក់សាំង ប្រកបដោយប្រសិទ្ធភាព និងជោគជ័យរហូតមកដល់ពេលនេះ មានរយៈពេលជាង ៤០ថ្ងៃ ហើយដែលគ្មានអ្នកឆ្លងជំងឺកូវីដ-១៩។ ប្រទេសកម្ពុជាត្រូវបានចាត់ទុកថា ជាគោលដៅទេសចរណ៍សុវត្ថិភាព។ ជាមួយគ្នានេះ បើតាមការព្យាករណ៍សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនក្នុងអត្រា៥,៤% ក្នុងឆ្នាំ២០២២ និង៦,៦% ក្នុងឆ្នាំ២០២៣។

សម្ដេចប្រធានព្រឹទ្ធសភាបានស្នើឱ្យគណៈប្រតិភូជំរុញទេសចរអារ៉ាប៊ីសាអូឌីត ក៏ដូចជាទេសចរមកពីបណ្តាប្រទេសជាសមាជិកនៃសម្ព័ន្ធពិភពឥស្លាម មកទស្សនាកម្ពុជាឱ្យបានច្រើន និងជួយជំរុញឱ្យមានការហោះហើរឡើងវិញដោយក្រុមហ៊ុនអាកាសចរណ៍អារ៉ាប់អេមីរ៉ាត់មករាជធានីភ្នំពេញ និងខេត្តសៀមរាប។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលអារ៉ាប៊ីសាអូឌីត ដែលបានផ្តល់អាហារូបករណ៍ដល់និស្សិតខ្មែរ-អ៊ីស្លាម សម្រាប់ថ្នាក់ឧត្តមសិក្សាផ្នែកអក្សរសាស្ត្រអារ៉ាប់ និងសាសនា និងអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ អនុបណ្ឌិត និងបណ្ឌិតចំនួន៨៥កន្លែងដល់និស្សិតកម្ពុជាក្នុងឆ្នាំសិក្សា២០១៩-២០២០។

សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរឱ្យចំណងមិត្តភាពរវាងប្រទេសទាំងពីរស្ថិតស្ថេរចីរកាល និងប្រសិទ្ធពរជូនគណៈប្រតិភូមានសុខភាពល្អបរិបូរណ៍ និងទទួលបានភាពរីករាយក្នុងការស្នាក់នៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់យ៉ារីន)

# ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភាអញ្ជើញបញ្ចុះបឋមសិលាសាងសង់ព្រះវិហារនៅវត្តលុម្ពិនី ហៅវត្តអូរសោម នៅខេត្តពោធិ៍សាត់





*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញជាអធិបតីភាពក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារ*

នាព្រឹកថ្ងៃចន្ទ ទី៣០ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារ នៅវត្តលុម្ពិនី ហៅវត្តអូរសោម ស្ថិតនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ក្នុងឱកាសនោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានអញ្ជើញអុជធូបបួងសួងលោកតាសោម និងធ្វើពិធីក្រុងពាលីបួងសួងសុំម្ចាស់ទឹកម្ចាស់ដី ដើម្បីសាងសង់ព្រះវិហារទៅតាមប្រពៃណីព្រះពុទ្ធសាសនា។ ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានបញ្ជាក់ថា ដោយចង់ឃើញពីក្ដីស្រមៃរបស់បងប្អូនប្រជាពលរដ្ឋចង់បាននូវព្រះវិហារថ្មី ឯកឧត្តមបានរួមកម្លាំងសទ្ធាជ្រះថ្លាជាមួយនឹងសមាជិក សមាជិកាព្រឹទ្ធសភា និងសប្បុរសជននានា ដើម្បីរួមគ្នាកសាងនូវព្រះវិហារឱ្យរួចរាល់នៅខែមេសា ឆ្នាំ២០២៣ ខាងមុខនេះ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានបញ្ជាក់ថា ដោយសារប្រទេសយើងមានសុខសន្តិភាព ស្ថិរភាពនយោបាយល្អ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ធ្វើឱ្យប្រជាជនគ្រប់រូបកំពុងសប្បាយរីករាយនូវសមិទ្ធផលជាច្រើន មានជាអាទិ៍៖ ហេដ្ឋារចនាសម្ព័ន្ធជាពិសេសផ្លូវជាតិលេខ១០ ដែលកំពុងធ្វើការសាងសង់ក្នុងឃុំអូរសោម នឹងក្លាយជាសរសៃឈាមសេដ្ឋកិច្ច លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅឃុំអូរសោម ទាំងមូលងាយស្រួលក្នុងការធ្វើដំណើរ និងនាំយកដំណាំ





*ប្រជាពលរដ្ឋចូលរួមក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារ*





*ទិដ្ឋភាពក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារ*

កសិផលរបស់ខ្លួនទៅលក់នៅទីផ្សារ ដើម្បីឱ្យមានជីវភាពរស់នៅកាន់តែប្រសើរឡើងថែមទៀត។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខន** បានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ឱ្យចូលរួមថែរក្សាការពារសុខ-ភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារឱ្យបានល្អ ព្រមទាំងបានជំរុញ និងលើកទឹកចិត្តដល់អាជ្ញាធរ និងក្រុមប្រឹក្សាឃុំ និងប្រជា-ពលរដ្ឋអញ្ជើញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ដើម្បីជ្រើសរើសនូវថ្នាក់ដឹកនាំដ៏ល្អសម្រាប់អភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន ក៏ដូចជាប្រទេសជាតិឱ្យមានការរីកចម្រើនខ្លាំងលើគ្រប់វិស័យបន្ថែមទៀត។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខន** បានសំណូមពរទៅភាគីចិនដែលកំពុងសាងសង់ផ្លូវជាតិលេខ១០ ក្នុងអំឡុងពេលសាងសង់សូមកាត់បន្ថយនូវផលប៉ះពាល់ និងផល-រំខានដល់ប្រជាពលរដ្ឋ និងសុំការយោគយល់ពីសំណាក់បងប្អូនប្រជាពលរដ្ឋ ពីព្រោះក្រោយការសាងសង់រួចផ្លូវនេះជួយផលប្រយោជន៍យ៉ាងច្រើនដល់បងប្អូនប្រជាពលរដ្ឋ។

សូមជម្រាបថា ព្រះវិហារដែលត្រូវសាងសង់នេះមានទំហំ៩,២០មx១៤,៦០ម សាងសង់រយៈពេល១១ខែ ចាប់ពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣។

វត្តអូរសោមត្រូវបានបង្កើតឡើងនៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៩។ ដំបូងឡើយវត្តអូរសោម មានតែកុដិឈើចំនួន១ខ្នងតែប៉ុណ្ណោះ រហូតមកដល់ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៨ សាលាឆាន់១ខ្នង បានសាងសង់រួចរាល់ជាស្ថាពរ ក្រោមការផ្តួចផ្តើមរបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខន** អនុ-ប្រធានទី២ព្រឹទ្ធសភា និងបានបំពាក់នូវបង្គោល និងអំពូល-ភ្លើងដោយប្រើសូឡាសម្រាប់បំភ្លឺនៅក្នុងបរិវេណវត្ត៕

(អត្ថបទ៖ នុត សច្ចៈ និងរូបភាព៖ គង់ យ៉ារីន)






*ទិដ្ឋភាពក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារ*

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២-២០២៧ នៅវិទ្យាល័យវត្តកោះ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) នៅវិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានអញ្ជើញបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២-២០២៧ នៅវិទ្យាល័យបឹងត្របែក សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានអញ្ជើញចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) នៅវិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម កិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា បានអញ្ជើញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២-២០២៧ នៅក្នុងសាលាគរុកោសល្យ និងវិក្រឹត្យការក្រុងតាខ្មៅ ខេត្តកណ្តាល។



❈នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម កិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) នៅវិមានព្រឹទ្ធសភា៕



# ព្រឹទ្ធសភាទទួលជំនួយសម្ភារវេជ្ជសាស្ត្រពីអង្គការចែករំលែកសង្គ្រោះអាយុជីវិតសកល នៃសាធារណរដ្ឋកូរ៉េ



ឯកឧត្តម ផាក ហ៊ឹងខ្យឹង និងឯកឧត្តម ម៉ម ប៊ុននាង អធិបតីភាពក្នុងពិធីប្រគល់-ទទួលជំនួយសម្ភារវេជ្ជសាស្ត្រ

សម្ភារវេជ្ជសាស្ត្រចំនួន២៣មុខ ដែលជាជំនួយមនុស្សធម៌ដ៏ថ្លៃថ្លារបស់អង្គការចែករំលែកសង្គ្រោះអាយុជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េ ត្រូវបានប្រគល់ជូនព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ អ្នកនាំពាក្យព្រឹទ្ធសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ផាក ហ៊ឹងខ្យឹង** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលសិក្ខាសាលាបណ្ណាល័យ វិមានព្រឹទ្ធសភា។

បន្ទាប់ពីការថ្លែងអំណរគុណ និងចំណាប់អារម្មណ៍របស់ក្រុមសម្របសម្រួលមូលនិធិចែករំលែកសង្គ្រោះជីវិតសកល និងចំណាប់អារម្មណ៍របស់លោក **គីម មីនហ្វ** តំណាងអង្គការចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ រួចមក ឯកឧត្តម **ផាក ហ៊ឹងខ្យឹង** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា បានសម្ដែងនូវសេចក្ដីរីករាយ និងចូលរួមអបអរសាទរចំពោះការប្រគល់-ទទួលសម្ភារវេជ្ជសាស្ត្រ ដែលជាជំនួយមនុស្សធម៌ដ៏ថ្លៃថ្លារបស់អង្គការចែករំលែកសង្គ្រោះអាយុជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ជូនដល់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ពិតជាសក្ខីភាពក្នុងការបញ្ជាក់នូវទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងសាធារណរដ្ឋកូរ៉េ និងព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានរំលឹកថា ក្នុងរយៈពេល២៥ឆ្នាំកន្លងទៅ ទំនាក់ទំនងទ្វេភាគី នៃប្រទេសទាំងពីរ មានការកើនឡើងជាលំដាប់ ជាពិសេសវិស័យអភិវឌ្ឍន៍ ក៏ដូចជា





ឯកឧត្តម ផាក ហ៊ឹងខ្យឹង និងឯកឧត្តម ម៉ម ប៊ុននាង អញ្ជើញឡើងថ្លែងសុន្ទរកថាក្នុងអង្គពិធី




*ទិដ្ឋភាពក្នុងពិធីប្រគល់-ទទួលជំនួយសម្ភារវេជ្ជសាស្ត្រ*

ការផ្លាស់ប្ដូរវប្បធម៌ នៃប្រទេសទាំងពីរ ហើយអ្វីដែលពិសេសជាងនេះទៅទៀត គឺប្រទេសកម្ពុជាជាដៃគូដ៏សំខាន់ក្នុងការទទួលបានជំនួយ ODA ដែលក្នុងឆ្នាំនេះប្រទេសកម្ពុជាបានទទួលជំនួយ១៥០លានដុល្លារអាមេរិកពីសាធារណរដ្ឋកូរ៉េ។ ក្នុងនោះ មានអង្គការសង្គមស៊ីវិលចំនួន១៧របស់កូរ៉េ ដែលកំពុងធ្វើសកម្មភាពលើវិស័យជាច្រើននៅប្រទេសកម្ពុជា ជាពិសេសអង្គការសង្គមស៊ីវិលក្នុងវិស័យអប់រំជាវិស័យមួយដ៏សំខាន់ក្នុងការជួយលើកកម្ពស់ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ម ប៊ុននាង** បានមានប្រសាសន៍ថា ថ្ងៃនេះព្រឹទ្ធសភាកម្ពុជាពិតជាមានសេចក្ដីសោមនស្សរីករាយក្រៃលែង ដោយបានទទួលជំនួយមនុស្សធម៌ជាសម្ភារ ឧបករណ៍វេជ្ជសាស្ត្រ ពីអង្គការចែករំលែកជួយសង្គ្រោះជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េ។ ជំនួយមនុស្សធម៌ដ៏ថ្លៃថ្លានេះ គឺជាសក្ខីភាពដ៏ពិតប្រាកដនៃចំណងមិត្តភាព សាមគ្គីភាពរវាងកម្ពុជា-កូរ៉េ ជាពិសេសរវាងព្រឹទ្ធសភាកម្ពុជាជាមួយនឹងអង្គការចែករំលែកសង្គ្រោះអាយុជីវិតសកល ពិតជាឆ្លើយតបនឹងតម្រូវការជាក់ស្ដែងរបស់ព្រឹទ្ធសភា ក៏ដូចជារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការលើកកម្ពស់សេវាសុខភាពសាធារណៈ ការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺកាចសាហាវនានា ជាអាទិ៍៖ ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម ជំងឺកូវីដ-១៩ ជាដើម។ល។ ដើម្បីធានាបាននូវការងើបឡើងវិញយ៉ាងឆាប់រហ័សនៃសកម្មភាពសង្គម-សេដ្ឋកិច្ច។

ឯកឧត្តម **ម៉ម ប៊ុននាង** បានបញ្ជាក់ថា ជំនួយមនុស្សធម៌ដូចដែលយើងទាំងអស់គ្នាបានឃើញជាក់ស្ដែងនេះ នឹងត្រូវគ្រប់គ្រងដោយថ្នាក់ដឹកនាំព្រឹទ្ធសភា ហើយប្រើប្រាស់តាមរយៈយន្តការនានានៃព្រឹទ្ធសភា សម្រាប់ចែកជូនដល់មន្ទីរពេទ្យរដ្ឋ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនានា ព្រមទាំងប្រជាជននៅក្នុងបណ្ដាភូមិភាគទាំង៨។ ជាមួយគ្នានេះ ព្រឹទ្ធសភាកម្ពុជាមានសេចក្ដីរីករាយ និងសូមស្វាគមន៍នូវរាល់កិច្ចសហការមនុស្សធម៌ ជាមួយនឹងអង្គការចែករំលែកសង្គ្រោះជីវិតសកលជាបន្តបន្ទាប់ទៀត។

ក្នុងនាមថ្នាក់ដឹកនាំព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងសហការីទាំងអស់ ឯកឧត្តម **ម៉ម ប៊ុននាង** បានថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការចែករំលែកសង្គ្រោះជីវិតសកល ដែលបានផ្ដល់នូវជំនួយមនុស្សធម៌ ដើម្បីលើកកម្ពស់គុណភាពជីវិត និងជួយសង្គ្រោះជីវិតប្រជាជនកម្ពុជា៕

(អត្ថបទ៖ វង់ សុជាតិ និងរូបភាព៖ គង់ យ៉ារីន)




*ឯកឧត្តម ម៉ម ប៊ុននាង ទទួលជំនួយសម្ភារវេជ្ជសាស្ត្រ*

# ព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប និមន្ត និងអញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា




ឯកឧត្តម ម៉ាន់ ឈឿន (ឆ្វេង) អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា

ក្នុងឱកាសទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា របស់ព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុបចំនួន២០០នាក់ នាព្រឹកថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញធ្វើបទបង្ហាញ ស្ដីពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា។

ឯកឧត្តម **ម៉ាន់ ឈឿន** បានបញ្ជាក់ថា ការរីកវិវឌ្ឍនយោបាយនៅលើសកលលោកបាននាំឱ្យប្រទេសជាច្រើនងាកមកប្រកាន់របបគ្រប់គ្រងរដ្ឋ តាមបែបប្រជាធិបតេយ្យ ពហុបក្ស អាស្រ័យសភា និងសេដ្ឋកិច្ចទីផ្សារសេរី។ ព្រះរាជាណាចក្រកម្ពុជាបានប្រកាន់យករបបសភាពីរថ្នាក់ គឺព្រឹទ្ធសភា និងរដ្ឋសភា សម្រាប់ផ្ដល់ប្រយោជន៍យ៉ាងសំខាន់ក្នុងការកសាងច្បាប់ ដើម្បីបម្រើឱ្យការគ្រប់គ្រងសង្គមបានគ្រប់គ្រាន់ ប្រកបដោយគុណភាព។

ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងនាថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ដោយការតែងតាំង។ ចាប់ពីនីតិកាលទី២ ព្រឹទ្ធសភាកើតឡើងតាមរយៈការបោះឆ្នោតអសកលមិនចំពោះ តាមវិធីជ្រើសរើសបោះឆ្នោតជាសម្ងាត់។ ព្រឹទ្ធសភាមានសមាជិកស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភា គឺមានចំនួន៦២រូប។ សមាជិក២រូបចាត់តាំងដោយព្រះមហាក្សត្រ សមាជិក២រូបជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀប និងសមាជិក៥៨រូបទៀត ជ្រើសតាំងដោយការបោះឆ្នោតជាអសកល នៅតាមបណ្ដាភូមិភាគទាំង៨ ទូទាំងប្រទេស។ អ្នកបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងរាស្ត្រក្នុងតំណែង ហើយអាណត្តិរបស់ព្រឹទ្ធសភាមានរយៈពេល៦ឆ្នាំ។

ព្រឹទ្ធសភាមានមុខងារស្នូលចំនួន៣គឺ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។ ក្រៅពីមុខងារស្នូលទាំង៣ ព្រឹទ្ធសភាមានមុខងារគាំទ្រចំនួន២ទៀត គឺមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន។

ព្រឹទ្ធសភាមានគណៈកម្មការជំនាញចំនួន១០ មានតួនាទីជាសេនាធិការឱ្យព្រឹទ្ធសភាក្នុងការបំពេញមុខងារនីតិកម្ម មុខងារត្រួតពិនិត្យ និងមុខងារព័ត៌មាន ដោយធានាការប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួនជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា។

បន្ទាប់ពីបានស្ដាប់ការធ្វើបទបង្ហាញរួចមក ព្រះសង្ឃ សាស្ត្រាចារ្យ និស្សិតនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ក៏បាននិមន្ត និងអញ្ជើញទស្សនាកន្លែងធ្វើការសំខាន់ៗរបស់ព្រឹទ្ធសភាមានជាអាទិ៍៖ បណ្ណាល័យ សាលប្រជុំពេញអង្គ សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងអគារប្រវត្តិសាស្ត្រនានា នៅក្នុងបរិវេណវិមានព្រឹទ្ធសភា៕

(អត្ថបទ និងរូបភាព៖ វង់ សុជាតិ)



ព្រះសង្ឃ សាស្ត្រាចារ្យ និស្សិតនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប និមន្ត និងអញ្ជើញមកបំពេញទស្សនកិច្ចនៅវិមានព្រឹទ្ធសភា

# សាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដា ទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា



*ឯកឧត្តម ម៉ែន-ស៊ីផាន់ អញ្ជើញធ្វើបទបង្ហាញ*

សាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដាចំនួន៩០នាក់ បានអញ្ជើញមកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៦ ខែឧសភា ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភា។ តាមរយៈដំណើរទស្សនកិច្ចនេះ សាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដា មានឱកាសជួបសំណេះសំណាល និងស្តាប់បទបង្ហាញរបស់ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាស្តីពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា និងដំណើរការធ្វើច្បាប់របស់ព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ែន-ស៊ីផាន់** បានជម្រាបអំពីប្រវត្តិ និងគោលបំណង នៃការបង្កើតព្រឹទ្ធសភា ដែលក្នុងនោះ គឺការបញ្ចប់វិបត្តិនយោបាយ លើកកម្ពស់ការបង្រួបបង្រួមផ្សះផ្សាជាតិ និងពង្រឹងស្ថិរភាពនយោបាយ។ ព្រឹទ្ធសភាកើតឡើងដោយសារការបោះឆ្នោតអសកលមិនចំពោះ ដែលសមាជិកព្រឹទ្ធសភាចំនួន២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ២រូបត្រូវបានជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀប និងសមាជិកព្រឹទ្ធសភា៥៨រូបទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកលមិនចំពោះ។ អង្គបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺតំណាងរាស្ត្រ និងក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសក្នុងមុខតំណែង។

ឯកឧត្តមបានបញ្ជាក់ទៀតថា ព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំហើយរហូតមកដល់ពេលនេះ ព្រឹទ្ធសភាបានឈានដល់នីតិកាលទី៤ ដែលមានគណៈកម្មការជំនាញចំនួន១០។ គណៈកម្មការនីមួយៗ មានតួនាទី ភារកិច្ចជាសេនាធិការឱ្យព្រឹទ្ធសភា ដើម្បីជួយជ្រោមជ្រែងព្រឹទ្ធសភាក្នុងការតាក់តែង និងប្រតិបត្តិច្បាប់ឱ្យកាន់តែប្រសើរឡើង។ ព្រឹទ្ធសភាមានមុខងារចំនួន៣ គឺ៖មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។ ក្រៅពីមុខងារទាំង៣នេះ ព្រឹទ្ធសភាក៏បានចូលរួមចំណែកជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែល្អប្រសើរឡើង ក្នុងការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងការគ្រប់គ្រងប្រទេសប្រកបដោយតម្លាភាព និងគណនេយ្យភាពយ៉ាងពិតប្រាកដ។

បន្ទាប់មកសាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដា បានអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានាក្នុងបរិវេណព្រឹទ្ធសភា៕

(អត្ថបទ និងរូបភាព៖ វង់ សុជាតិ)



*ទិដ្ឋភាពសាស្ត្រាចារ្យ និស្សិតនៃវិទ្យាស្ថានវ៉ាន់ដា ស្តាប់បទបង្ហាញ*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❋នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ស្តីពីការត្រៀមរៀបចំពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ ក្នុងក្រុងក្រចេះ ខេត្តក្រចេះ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។



❋នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយនឹងសភានិយាយភាសាបារាំង ដើម្បីពិនិត្យ និងពិភាក្សាត្រៀមចូលរួមមហាសន្និបាតលើកទី៤៧ នៃសភាប្រើភាសាបារាំង (APF) ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២២ នៅទីក្រុងគីហ្គាលី ប្រទេសរវ៉ាន់ដា នាពេលខាងមុខ នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។

❋ឯកឧត្តម **ម៉ុម ឌឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំ៖



-ក្រុមការងារ APF ដើម្បីត្រៀមអញ្ជើញចូលរួមមហាសន្និបាតលើកទី៤៧ នៃសភាប្រើភាសាបារាំង នៅទីក្រុងហ្គីហ្គាលី ប្រទេសរវ៉ាន់ដា ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២២ នាពេលខាងមុខ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២។

-ស្តីពីការបែងចែកការងារ និងស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីត្រៀមចុះបំពេញបេសកកម្មទៅខេត្តព្រះសីហនុ នៅសាលប្រជុំគណៈកម្មការទី៧ នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២។



❋នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ដើម្បីពិនិត្យ និងពិភាក្សាលើឯកសារត្រៀមផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងសារព័ត៌មានវីអូឌី (VOD) នៃមជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ស៊ីស៊ីអាយអ៊ឹម) នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។



❋នាព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ស្តីពី សកម្មភាព លទ្ធផលការងារ និងរបាយការណ៍ថវិការបស់គណៈកម្មការប្រចាំខែមិថុនា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❋នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំពិនិត្យ និងកែសម្រួលឯកសារពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីត្រៀមចុះបំពេញបេសកកម្មទៅខេត្តព្រះសីហនុ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❋ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភាបានអញ្ជើញ៖

-ប្រជុំជាមួយនឹងលោកជំទាវ **ខាំ សុគន្ធា** អភិបាលរងខេត្តក្រចេះ ដើម្បីពិនិត្យពិភាក្សាលើបញ្ហាផ្សេងៗ ដើម្បីត្រៀមរៀបចំពិធីអបអរសាទរខួបលើកទី៧៣ នៃទិវាកុមារអន្តរជាតិ ១មិថុនា ឆ្នាំ២០២២ នៅគេហដ្ឋានរបស់ឯកឧត្តម ស្ថិតក្នុងសង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០២២។

-ពិនិត្យទីតាំងសម្រាប់ត្រៀមរៀបចំពិធីអបអរសាទរខួបទី៧៣ នៅក្នុងសាលាបឋមសិក្សារកាកណ្តាលក្នុង សង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។

❋នាថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ខាវ ខេង** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយនឹងភ្នាក់ងារសង្កេតការណ៍ក្នុងការបោះឆ្នោត ដើម្បីត្រៀមលក្ខណសម្បត្តិចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសង្កាត់ អាណត្តិទី៥ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ នៅសាលាសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យ និងជំរុញការងារសាងសង់រោងចក្រផលិតចំណីសត្វ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងប្រមូលផលស្រូវ ព្រមទាំងចុះពិនិត្យមើលទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករកំពុងប្រមូលផលស្រូវ ព្រមទាំងដឹកនាំក្រុមការងារចុះពិនិត្យទំនប់ទឹក និងគ្រឿងចក្រជីកប្រឡាយប្រវែង២.៥០០ម៉ែត្រ ដើម្បីរំដោះជំនន់ទឹកភ្លៀង នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករដែលកំពុងប្រមូលផលផ្លែទុរេន ព្រមទាំងចុះពិនិត្យមើលកសិដ្ឋានចិញ្ចឹមជ្រូក និងពិនិត្យមើលសកម្មភាពដាំដើមឈើបេងនៅតាមជើងភ្នំ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមការងារសាងសង់ទ្រុងជ្រូកកសិដ្ឋានទី៣ និងប្រជាពលរដ្ឋដែលកំពុងនេសាទ ព្រមទាំងចុះពិនិត្យទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា នៅជើងភ្នំកំចាយបូកគោ ភូមិអង្គង់ក្រពើ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងចុះណែនាំកម្មករអំពីរបៀបថែទាំដំណាំដាំដុះ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងណែនាំកម្មករអំពីរបៀបតែងមែកស្វាយ ព្រមទាំងសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋដែលអញ្ជើញសម្រាកកម្សាន្ត និងទស្សនាសួនសត្វ នៅតំបន់កសិ-ទេសចរណ៍ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០២២។

❋នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារថ្នាក់ស្រុកជាមួយនឹងក្រុមប្រឹក្សាឃុំ ស្តីពី “ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ទាំង៧ចំណុច” នៅស្រុកកំពង់សៀម ស្រុកកងមាស ស្រុកកោះសូទិន ស្រុកចំការលើ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

❋ឯកឧត្តម **ម៉ុម ឌឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ឃ្មួញ



ដើម្បីស្ដាប់ពីស្ថានភាពការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងការងារផ្ដល់សេវាជូនប្រជាពលរដ្ឋ នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ភ្លើងឆេះរទេះ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខ សណ្ដាប់ធ្នាប់ ការផ្ដល់សេវា-សាធារណៈ និងការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅខណ្ឌកំបូល រាជធានី-ភ្នំពេញ នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់គោករកា ដើម្បីស្ដាប់ពីស្ថានភាពការងារសន្តិសុខ សណ្ដាប់-ធ្នាប់សាធារណៈ និងការផ្ដល់សេវាជូនប្រជាពលរដ្ឋ នៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ នាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។

❋នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងមន្ត្រីបម្រើការងារនៅពុទ្ធសាសនបណ្ឌិត្យ ដើម្បីឈ្វេងយល់



អំពីសកម្មភាពការងារ និងរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងឧបត្ថម្ភនូវថវិកាមួយចំនួន។

❋លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះនៅឃុំអំពិលក្រៅ ឃុំព្រៃទឹង ឃុំព្រែកចង្ក្រាន ឃុំឫស្សីសាញ់ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែឧសភា និងចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងពិធីជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ជនចាស់ជរា យុវជន យុវនារី និងកុមារ សរុបចំនួនជាង៤០០នាក់ នៅភូមិក្បាលថ្នាល់ ឃុំសែប ស្រុកកំពុងត្រឡាច ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២។

❋នាថ្ងៃទី២៨ ថ្ងៃទី២៩ និងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅឃុំមួយចំនួន ស្ថិតក្នុងស្រុកភ្នំក្រវាញ និងស្រុកវាលវែង ខេត្តពោធិ៍សាត់។

❋នាថ្ងៃទី២៨ និងថ្ងៃទី៣០ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាន** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំត្រពាំងវែង និងឃុំគោកត្រប់ ដើម្បីឈ្វេងយល់អំពីការងារថែរក្សាសន្តិសុខ សុវត្ថិភាព និងរបៀបរៀបរយសាធារណៈក្នុងមូលដ្ឋាន នាអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

អាណត្តិទី៥ នៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

❋ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមកិច្ចប្រជុំសំណេះសំណាល និងសួរសុខទុក្ខជាមួយនឹងថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ទូទាំងខេត្តតាកែវ តាមប្រព័ន្ធវីដេអូ(Zoom) នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។

❋នាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាអធិបតីភាពក្នុងពិធីបញ្ចុះបឋមសិលាចាប់ផ្ដើមសាងសង់ស្នាក់ការឃុំឫស្សីស្រុកចំនួនមួយខ្នង ដែលមានទំហំ ទទឹង៦ម៉ែត្រ បណ្ដោយ១១ម៉ែត្រ សាងសង់អំពីបេតុងប្រក់ក្បឿង នៅឃុំឫស្សីស្រុក ស្រុកពាមជរ ខេត្តព្រៃវែង។

❋ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីជួបសំណេះសំណាលជាមួយនឹងអាជីវករពាណិជ្ជករ សហគ្រិនវ័យក្មេងចំនួន១.០០០នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលមហោស្រពសង្កែ ព្រមទាំងសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងស្រុកមោងឫស្សី និងស្រុកគាស់ក្រឡ ខេត្តបាត់ដំបង នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងស្រុករតនមណ្ឌល និងស្រុកសង្កែ នៅខេត្តបាត់ដំបង នាព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។

❋នាថ្ងៃទី២៦ ខែឧសភា ថ្ងៃទី២ និងទី៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥(ឆ្នាំ២០២២-២០២៧) នៅភូមិបាក់រនាស់ ឃុំតានូន ស្រុកបូទុមសាគរ ឃុំជីផាត ស្រុកថ្មបាំង ខេត្តកោះកុង។

❋ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលក្រាបថ្វាយបង្គំសម្ដេចព្រះវនរ័តកិត្តិបណ្ឌិត **ណយ ច្រឹក** សម្ដេចព្រះសង្ឃនាយករងទី២ នៃគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តចន្ទបុរីវង្ស ព្រមទាំងប្រគេនបច្ច័យមួយចំនួនសម្រាប់កសាងសមិទ្ធផលនានា នៅក្នុងបរិវេណវត្តចន្ទបុរីវង្ស រាជធានីភ្នំពេញ នាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។



-ឧបត្ថម្ភអាវរងាជូនមន្ត្រីលេខាធិការដ្ឋាន សន្តិសុខ និងបុគ្គលិកផ្នែកអនាម័យ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ម្នាក់ៗទទួលបានអាវរងា ចំនួន១នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២។



-ជួបសំណេះសំណាល ព្រមទាំងឧបត្ថម្ភអាវយឺត កន្សែងពោះគោ និងម៉ាស់ ជូនក្រុមយុវជនភូមិ៧ និងភូមិ៩ ដែលកំពុងមមាញឹកលាបគំនូសពណ៌តាមចិញ្ចើមផ្លូវសំខាន់ៗ នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២។



-ជួបសំណេះសំណាល ព្រមទាំងឧបត្ថម្ភអង្ករ១០០គីឡូក្រាម និងកន្សែងពោះគោ១០ ជូននគរបាលរដ្ឋបាល និងប្រជាការពារ ដែលខិតខំរក្សាបានសន្តិសុខ សុវត្ថិភាពបានល្អប្រសើរ នៅសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២។

❈នាថ្ងៃទី២៩ ខែឧសភា និងថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះនៅភូមិក្តាន់រយ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២១ ថ្ងៃទី២៤ ខែឧសភា ថ្ងៃទី១ និងថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋតាមខ្នងផ្ទះទូទាំងឃុំព្រះពន្លា ចំនួន២៨ខ្នងផ្ទះ ព្រមទាំងជូនអំណោយក្នុង១គ្រួសារ ទទួលបាន៖ សារុង១ និងថវិកាមួយចំនួន ព្រមទាំងចូលរួមរំលែកទុក្ខគ្រួសារនៃសពចំនួន២គ្រួសារ និងឧបត្ថម្ភថវិកាមួយចំនួនសម្រាប់ជូនក្រុមប្រឹក្សាឃុំ នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២។

❈ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋនៅក្នុងឃុំស្តុះ ឃុំក្រាំងអំពិល និងឃុំធម្មតាអរ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** អ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ស្ពឺ ស្ថិតក្នុងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៧ និងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំរលាំងគ្រើល ឃុំរលាំងចក និងឃុំសែនដី ដើម្បីឈ្វេងយល់អំពីការងារថែរក្សាសន្តិសុខ សុវត្ថិភាព និងរបៀបរៀបរយសាធារណៈក្នុងមូលដ្ឋាន នាអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៣១ ខែឧសភា និងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។

-ចុះសួរសុខទុក្ខលោកជំទាវ **ទឹម អ៊ីន** ជំនួយការសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន និងឧបត្ថម្ភទឹកដោះគោចំនួន២យួរ ទឹកត្រចៀកកាំ១ប្រអប់ ទឹកបរិសុទ្ធ១កេស និងថវិកាមួយចំនួន នៅភូមិស្វាយក្រវ៉ាន់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យខួប១០០ថ្ងៃ ម្តាយលោកជំទាវ **កែវ សុខុម** សមាជិកាក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ នៅភូមិត្រស់សាលា សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់-

ស្ទឹ នារសៀលថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុកសំរោងទង នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២។

❀នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញត្រួតពិនិត្យការងារពាក្យបណ្ដឹងសុំអន្តរាគមន៍របស់ប្រជាពលរដ្ឋ នៅខេត្តកំពង់ចាម ។

❀ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ នៅឃុំឈ្នួលមានជ័យ ឃុំភ្នំលាប ឃុំទឹកជោរ និងឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ នៅឃុំទានកាំ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក ដើម្បីពិនិត្យការងារសម្រេចបាននាពេលកន្លងមក នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសម្ពោធបើកការដ្ឋានកសាងផ្លូវចំនួន៤ខ្សែ រួមមាន៖ ផ្លូវក្រាលកៅស៊ូ DBST ចំនួន១ខ្សែប្រវែង៦.៥៦៧ម៉ែត្រ ផ្លូវចាក់បេតុង១ខ្សែប្រវែង៣៩០ម៉ែត្រ ផ្លូវចាក់បេតុង១ខ្សែប្រវែង១.៧០០ម៉ែត្រ ផ្លូវក្រាលថ្មបំបែក១ខ្សែប្រវែង១.៧០០ម៉ែត្រ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២។

❀នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វ៉ាយ អិល ភី ម.ក សាខាស្រុកថ្មពួក ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

❀ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំគ្រួស និងឃុំឈើទាល ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋ-មន្ត្រីក្រសួងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចនៅក្រុងបាវិត ខេត្តស្វាយរៀង នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២។

❀ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈ-កម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងជំរុញប្រជាពលរដ្ឋឱ្យទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឱ្យបានគ្រប់ៗគ្នា នៅឃុំសារង្គ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣១ ខែឧសភា ថ្ងៃទី១ និងថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបដកស្រង់បទពិសោ-ធន៍ ចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមលើការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅសាលប្រជុំសាលាស្រុកស្វាយចេក ខេត្តបន្ទាយមាន-ជ័យ នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២។

❋លោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈ-កម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្ទង់ផ្ទះ នៅផ្លូវលេខ ៩៧A ភូមិ៤ និងភូមិ៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី២៨ និងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២។

-រៀបចំពិធីជួបសំណេះសំណាលជាមួយនឹងអ្នកសង្កេត-ការណ៍ជាស្ត្រីរបស់អនុសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខណ្ឌចំការមន ចំនួន៨៥នាក់ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅខណ្ឌចំការមន រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីជួបសំណេះសំណាលពង្រឹងស្មារតីភ្នាក់ងារសង្កេតការណ៍ និងបណ្ដុះបណ្ដាលអំពីរបៀបរាយ-ការណ៍ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីជួបសំណេះសំណាល និងថ្លែងអំណរ-គុណដល់ប្រជាពលរដ្ឋរស់នៅក្នុងភូមិ២ និងភូមិ៥ ដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ កន្លងមក នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នារសៀលថ្ងៃទី១០ និងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២។

❋ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងសួរ-សុខទុក្ខប្រជាពលរដ្ឋ នៅស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២។

-នាំយកថវិកាមួយចំនួនប្រគល់ជូនលោក **នួន ថូ** ក្រុម-ប្រឹក្សាស្រុកស៊ីធរកណ្ដាល ដើម្បីឧបត្ថម្ភជូនដល់រដ្ឋបាលឃុំ ទាំង១១ឃុំ និងឧបត្ថម្ភថវិកាមួយចំនួនជូនរដ្ឋបាលឃុំ និងស្រុក នៅស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២។

❋ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្ទង់ផ្ទះ និងអំពាវនាវដល់ប្រជាពលរដ្ឋឱ្យពិនិត្យឡើងវិញនូវឯកសារបម្រើឱ្យការបោះឆ្នោត និងអញ្ជើញទៅបោះ-ឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់ៗគ្នា នៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣១ ខែឧសភា និងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងអំពាវនាវដល់ប្រជាពលរដ្ឋឱ្យពិនិត្យឡើងវិញនូវឯកសារបម្រើឱ្យការបោះឆ្នោត និងអញ្ជើញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់ៗគ្នា នៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២ និងថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២។

❋នាថ្ងៃទី៣ និងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ថុង ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខប្រជា-ពលរដ្ឋនៅស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ ក្នុងខេត្តកោះកុង។

❋ឯកឧត្តម **ខឹម លាវ** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមប្រជុំដកបទពិសោធន៍ការងារ ស្រុកជើងព្រៃ នៅសាលាស្រុកជើងព្រៃ ខេត្តកំពង់ចាម នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២។

❋ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំសាសនិកឥស្លាមនៅភូមិម៉ាក់ប្រាង្គ ស្រុកទឹក-ឈូ ខេត្តកំពត នាថ្ងៃសុក្រ ទី១០ ខែមិថុនា ឆ្នាំ២០២២។

-ចូលរួមរំលែកមរណទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព

ប្រជាពលរដ្ឋ នៅភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមរំលែកមរណទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព ប្រជាពលរដ្ឋ នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមរំលែកមរណទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព ប្រជាពលរដ្ឋ នៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០២២។



❈នារសៀលថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **សត ណារី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ ព្រឹទ្ធសភាចូលរួមគោរពវិញ្ញាណក្ខន្ធសពលោក **រស់ សរ** សមាជិកក្រុមប្រឹក្សាក្រុងសៀមរាប នៅភូមិគ្រឹះ ក្នុងភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

❈ឯកឧត្តម **សត ណារី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៧ឃុំ គឺឃុំខ្នារសណ្តាយ ឃុំព្រះដាក់ ឃុំចាន់ស ឃុំពពេល ឃុំតាយ៉ែក ឃុំសំរោង ឃុំខ្នារពោធិ៍ ស្រុកបន្ទាយស្រី ខេត្តសៀមរាប នាថ្ងៃទី២៦ ថ្ងៃទី២៨ ថ្ងៃទី៣០ ខែឧសភា និងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។

-នាំយកថវិកាជូនសាខាកាកបាទក្រហមខេត្តសៀមរាប ចំនួន២លានរៀល នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងអស់នៃខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅក្រុងសៀមរាប ខេត្តសៀម-រាប នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២។

❈ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីសំណេះសំណាលជាមួយនឹងលោក **ដួង ជីវិន** នាយកវិទ្យាល័យសម្តេចឪ និងលោកគ្រូ អ្នកគ្រូ អំពីការអភិវឌ្ឍក្រោមម្លប់នៃសន្តិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងអាជ្ញាធរមកពីបណ្តាស្រុកថ្មគោល និងស្រុកឯកភ្នំ ខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីរួមខេត្តបាត់ដំបង នារសៀលថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០២២។

❈ឯកឧត្តម **ស្រី បេន** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសម្ពោធឆ្លងសាលាធម្មសភា និងសមិទ្ធ-ផលនានា ក្នុងវត្តចែង ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯកបណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ស្ថិតក្នុងឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២។

-សំណេះសំណាលជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីសំណេះសំណាលជាមួយនឹងក្រុមយុវជន ក្រុមប្រឹក្សាក្រុង សង្កាត់ និងភូមិ ក្នុងក្រុងសំរោង ក្រោមអធិ-បតីភាពឯកឧត្តម **គន់ គីម** ទេសរដ្ឋមន្ត្រី នៃគណៈកម្មាធិ-

ការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន ស្ថិតនៅឃុំក្រសាំង ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ នាព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិ យុវជនឃុំទាំង៦ ដើម្បីពិនិត្យ និងតាមដានវឌ្ឍនភាពការងារ បញ្ហាប្រឈម និងវិធានការដោះស្រាយ ព្រមទាំងបានក្រើនរំលឹកប្រជាពលរដ្ឋ ទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឱ្យបានគ្រប់ៗគ្នា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២។

❈ឯកឧត្តម **អ៊ីង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖




-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈ និងការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២។

-ដឹកនាំកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំព្រៃគ្រី ដើម្បីស្តាប់សភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈ និងផែនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅសាលប្រជុំសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងគណៈអភិបាលស្រុក ក្រុមប្រឹក្សាស្រុក ក្រុមប្រក្សាឃុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខឯកឧត្តម **នន់ យ៉ៅ** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិត្រពាំងបី សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២។

❈ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងក្រុមយុវជនសង្កេតការណ៍ នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី២៥ ខែឧសភា ថ្ងៃទី២ និងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២។

-ចុះត្រួតពិនិត្យការជួសជុលផ្លូវមួយខ្សែប្រវែង១.២០០ម៉ែត្រ នៅភូមិអង្គក្នុង និងមួយខ្សែទៀតនៅភូមិអង្គក្រៅ នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២។

❈នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាមួយនឹងអនុសាខាកាកបាទក្រហមស្រុក

ដំណាក់ចង្អើរ ខេត្តកែប នាំយកអំណោយរបស់សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ឧបត្ថម្ភជូនប្រជាពលរដ្ឋរងគ្រោះដោយខ្យល់កន្ត្រាក់ប៉ើងដំបូលផ្ទះចំនួន៧ខ្នង ស្ថិតនៅក្នុងភូមិអំពេង និងភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។

❋នាថ្ងៃទី២៦ ថ្ងៃទី២៨ ថ្ងៃទី៣០ និងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ញៀម សាម៉ន** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅឃុំមួយចំនួន នៅស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

❋នាថ្ងៃទី២៥ ថ្ងៃទី២៧ ដល់ថ្ងៃទី២៩ និងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ លោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅឃុំមួយចំនួន ក្នុងខេត្តត្បូងឃ្មុំ។

❋នាថ្ងៃទី២៥ និងថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ព្រមទាំងអំពាវនាវដល់ប្រជាពលរដ្ឋឱ្យទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ទាំងអស់គ្នា នៅស្រុកអង្គរធំ និងស្រុកវ៉ារិន ខេត្តសៀមរាប។

❋លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកថវិកាមួយចំនួនឧបត្ថម្ភដល់សាខាកាកបាទក្រហមកម្ពុជា ខេត្តសៀមរាប ដើម្បីអបអរសាទរខួបលើកទី១៥៩ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០២២ ក្រោមប្រធានបទ៖ ទាំងអស់គ្នារួមជាមួយកាកបាទក្រហមកម្ពុជាដោះស្រាយបញ្ហាប្រឈមនានា និងបន្តពង្រឹងភាពធនសហគមន៍ នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ព្រមទាំងបានលើកទឹកចិត្តឱ្យប្រជាពលរដ្ឋទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឱ្យបានទាំងអស់គ្នា នៅស្រុកប្រាសាទបាគង ខេត្តសៀមរាប នាថ្ងៃទី២៦ ថ្ងៃទី២៨ និងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២។

-នាំយកទេយ្យទាន និងបច្ច័យទៅប្រគេនព្រះសង្ឃគង់នៅវត្តព្រះឥន្ទកោសីយ៍ រួមមាន៖ អង្ករ១បាវ ទឹកផ្លែឈើ ១កេស ផ្អក១គីឡូក្រាម និងថវិកាមួយចំនួន នៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ព្រមទាំងបានលើកទឹកចិត្តឱ្យប្រជាពលរដ្ឋទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឱ្យបានទាំងអស់គ្នា នៅស្រុកសូទ្រនិគម ខេត្តសៀមរាប នាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅស្រុកប្រាសាទបាគង និងស្រុកសូទ្រនិគម ខេត្តសៀមរាប នារសៀលថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២។

-ចុះឈ្វេងយល់អំពីលទ្ធផលនៃការបោះឆ្នោត និងសភាពការណ៍កើតក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនដល់ក្រុមប្រឹក្សាស្រុក ស្ថិតនៅស្រុកប្រាសាទបាគង ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២។

-ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសព លោក **អ៊ុំ ហ៊ាន** ដែលទទួលមរណភាពដោយជំងឺគាំងបេះដូង និងឧបត្ថម្ភបច្ច័យមួយចំនួន នៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២។

-ចុះសួរសុខទុក្ខឧបាសិកា **ឆយ ឆន** (ពិការភ្នែកទាំងពីរ) និងបានឧបត្ថម្ភថវិកាមួយចំនួន នៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❈នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២ សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) នៅវិមានព្រឹទ្ធសភា។

❈នាថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំអាយប៉ា (AIPACODD-5) នៅសាលបាយ័ន វិមានរដ្ឋសភា។

❈នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងព្រឹត្តិការណ៍ “ការប្រណាំងយានយន្តកម្ពុជា ជីស៊ីស៊ី ជ្រើសរើសជើងឯកឆ្នាំ២០២២” នៅភ្នំសែនជី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។



❈នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពិធីប្រគល់-ទទួលអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនដល់មន្ទីរពេទ្យគន្ធបុប្ផា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ស្ថិតនៅសាលសិក្ខាសាលាបណ្ណាល័យ វិមានព្រឹទ្ធសភា នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២។



❈នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីខួបលើកទី៤៥ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត (២០ មិថុនា ១៩៧៧ - ២០ មិថុនា ២០២២) និងសម្ពោធសមិទ្ធផលនានា នៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម X១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ផាម មិញ ជិញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្ថិតនៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។



❈នាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ នៃក្រុមអ្នកនយោបាយអាយប៉ាលើកទី១៣ នៅរដ្ឋសភា តាមរយៈប្រព័ន្ធនិម្មិត (Zoom) ក្រោមប្រធានបទចំនួន២ គឺ៖

១-ការអនុវត្តលើសេចក្តីសម្រេច នៃមហាសន្និបាតអាយប៉ាលើកទី៤២

២-កិច្ចសហប្រតិបត្តិការលើសេដ្ឋកិច្ចឌីជីថលក្នុងអាស៊ាន

ក្រោយវិបត្តិជំងឺកូវីដ-១៩ ។



❈នាថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធាន និងឯកឧត្តម **ឆាយ ទណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំត្រៀមរៀបចំមហាសន្និបាតអន្តរសភាអាស៊ានអាយប៉ា (AIPA) លើកទី៤៣ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា និងជាប្រធានគណៈកម្មការរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ នៅសាលបាយ័ន នៃវិមានរដ្ឋសភា។

❈នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំប្រចាំឆ្នាំលើកទី៥ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា ស្តីពីគ្រឿងញៀន ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ រដ្ឋសភា តាមប្រព័ន្ធនិម្មិត (Zoom) នៅសាលបាយ័ន វិមានរដ្ឋសភា។

❈នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **គឹម ឆា**



លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) នៅមន្ទីរពេទ្យបង្អែក ខេត្តស្វាយរៀង។



❈នាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំត្រៀមរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅខែវិច្ឆិកា ឆ្នាំ២០២២ ខាងមុខ ដែលសភាកម្ពុជាធ្វើជាម្ចាស់ផ្ទះ ក្រោមអធិបតីភាពលោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការទី៩រដ្ឋសភា និងជាប្រធានអនុគណៈកម្មការទី៣ "ឡូជីស្ទីក ពិធីការ និងបដិសណ្ឋារកិច្ច" នៃមហាសន្និបាតលើកទី៤៣ នៃអន្តរសភាអាស៊ានអាយប៉ា (AIPA) នៅសាលបាយ័ន វិមានរដ្ឋសភា៕

## ការទទួលពាក្យបណ្តឹង

❈នៅខែមិថុនា ឆ្នាំ២០២២ ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន៤ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៥ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន១ករណី កំពុងពិនិត្យសិក្សាចំនួន២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៧ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៥ករណី ធ្វើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងចម្លងជូនគណៈកម្មការនានារបស់ព្រឹទ្ធសភាចំនួន១៣ករណី៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងកំណត់ទិសដៅការងារខែមិថុនា ឆ្នាំ២០២២



*ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា*

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងលើកទិសដៅការងារសម្រាប់ខែមិថុនា ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍បូកសរុបនាពេលនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំបានជ្រាបអំពី សភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែឧសភាថា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានភាពមមាញឹកក្នុងការផ្តល់សេវាលើមុខងារនីតិកម្ម ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន៣លើក ប្រជុំពេញអង្គចំនួន១លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន១លើក បានដោយរលូន។ ក្នុងខែនេះផងដែរព្រឹទ្ធសភាបានចាប់ផ្តើមវិស្សមកាលរបស់ខ្លួនចាប់ពីថ្ងៃទី៣ ខែឧសភា ដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ហើយស្របនឹងដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាន់តែខិតជិតមកដល់។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់ ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានផ្តល់សេវាជូនគណៈកម្មការជំនាញទាំង ១០ ចុះបំពេញបេសកកម្ម ជួបសវនាការការងារ ជាមួយនឹងក្រសួង និងស្ថាប័ននានា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភាចូលរួមគោរពវិញ្ញាណក្ខន្ធ និងចុះជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ព្រមទាំងផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺ





*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា*





*ទិដ្ឋភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងលើកទិសដៅការងារខែមិថុនា ឆ្នាំ២០២២*

កូវីដ-១៩ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូអន្តរជាតិក្នុងការបង្កើនទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការបានកាន់តែល្អប្រសើរជាលំដាប់។

ទន្ទឹមគ្នានេះដែរ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបន្តយកចិត្តទុកដាក់ដល់មន្ត្រីរាជការទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធាន និងការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងល្អប្រសើរ។

សម្រាប់ខែមិថុនាខាងមុខ គឺឈានចូលដល់ពាក់កណ្តាលឆ្នាំ២០២២ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានបញ្ជាក់ថា ការសន្សំសំចៃថវិកាកាន់តែត្រូវរឹតបន្តឹង ដើម្បីគ្រប់-គ្រងតម្រូវការ និងដំណើរការឱ្យបានពេញលេញក្នុងឆ្នាំ២០២២។ ជាមួយគ្នានោះ ឯកឧត្តមបានកំណត់ឱ្យគ្រប់អង្គភាពចំណុះអគ្គលេខាធិកាដ្ឋានព្រឹទ្ធសភា បន្តផ្តល់សេវាជូនសមាជិកសមាជិកាព្រឹទ្ធសភាឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយលើមុខងារទាំង៥របស់ព្រឹទ្ធសភា ប្រកបដោយគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលា។

នៅក្នុងឱកាសនោះ ក៏មានការបញ្ចាំងវីដេអូបូកសរុបលទ្ធផលការងារខែឧសភា ឆ្នាំ២០២២ និងកិច្ចពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ការងារ បញ្ហាប្រឈម សំណូមពរព្រមទាំងមតិបូកសរុបរបស់ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខា-ធិការព្រឹទ្ធសភា។

(អត្ថបទ៖ វង់ សុជាតិ និងរូបភាព៖ គឹម សិទ្ធី)



*ទិដ្ឋភាពរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងលើកទិសដៅការងារខែមិថុនា ឆ្នាំ២០២២*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ



❈នារសៀលថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំការងារអំពីការគ្រប់គ្រងបុគ្គលិក នៃអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាបានទទួលជួបឯកឧត្តម Martin Vavra ឯកអគ្គរដ្ឋទូត វិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឆែក ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារអំពីការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា និងស្ថានទូតនៃសាធា-រណរដ្ឋឆែក នៅបន្ទប់ប្រជុំពិសេស វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាបានអនុញ្ញាតឱ្យលោក Maxime Johanet អតីតកម្មសិក្សាការីដែលបានធ្វើកម្មសិក្សារយៈពេល៦ខែ កាលពីឆ្នាំ២០១៨កន្លងទៅ នៅការិយាល័យហ្វ្រង់កូហ្វូនី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលជួបសម្តែងការគួរសម នៅការិយាល័យឯកឧត្តមអគ្គលេខាធិការវិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ ក្នុងនាមព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលក្រុមគ្រូពេទ្យមកពីមន្ទីរពេទ្យកាល់ម៉ែត ដែលបានរៀបចំការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) ជូនដល់ថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រី បុគ្គលិក នៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្តីពី ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ឡោយ ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (២០២៣-២០២៥) និងគម្រោងថវិកាឆ្នាំ២០២៣ របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **លីម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពីធីបើកវគ្គបណ្តុះបណ្តាលស្តីពី ជំនាញចាំបាច់ឌីជីថល សម្រាប់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធនិម្មិត (Zoom) នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **លីម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យ និងកែសម្រួលវីដេអូចំនួន២ខ្សែ គឺវីដេអូស្តីពី សមិទ្ធផលនានាដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិនដល់ព្រឹទ្ធសភាកម្ពុជា និងវីដេអូស្តីពី បណ្ណាល័យព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **លឹម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំការងារជាមួយនឹងអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ដោយមានការចូលរួមពីអង្គភាពចំណុះអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ចាប់ពីអនុប្រធាននាយកដ្ឋានឡើង នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី៩ ទី១០ ខែមិថុនា ឆ្នាំ២០២២ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ថ្នាក់ដឹកនាំខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៥) នៅវិមានព្រឹទ្ធសភា។



❈នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកព្រះរាជដង្វាយរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថ្វាយសម្ដេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម៨៦ យាងចូល ៨៧ព្រះវស្សា៕



